# បទពិសោធន៍ចិញ្ចឹមនិងព្យាបាលមាន់

**លោកអ៊ំ ងឹម យ៉ន ជាកសិករសនៅភូមិកណ្តាល ឃុំដូយ៉យ ស្រុកឈូក ខេត្តកំពត ។ គាត់មានបទពិសោធន៍ល្អក្នុងការចិញ្ចឹមមាន់ ដែលបច្ចេកទេសនេះផ្សព្វផ្សាយដោយអង្គការសេដាក ហើយគាត់បានធ្វើការរៀបចំចិញ្ចឹមក្នុងរយៈពេល ៥ ខែ គាត់ទទួលបានប្រាក់ចំណូលប្រមាណជា ១ លានរៀល ដោយមិនគិតពីការបរិភោគក្នុងគ្រួសារ ដែលខុសពីមុន សូម្បីតែបរិភោគក្នុងគ្រួសារក៏ពុំគ្រប់គ្រាន់ផង ។ ចំពោះបច្ចេកទេសនៃការចិញ្ចឹមមានបង្ហាញជូនដូចខាងក្រោម :**

## ១. ការរៀបចំទ្រុង ស្នូកទឹក និងស្នូកចំណី

ទ្រុងសំរាប់មាន់គាត់រៀបចំផ្សេងៗគ្នា គឺទ្រុងបង្ខាំងមាន់តូច និងទ្រុងមាន់ធំ ព្រមទាំងទីធ្លាសំរាប់ឲ្យមាន់ដើររកចំណីស៊ី ។



**កូនមាន់ស៊ីចំណីនៅក្នុងទ្រុង**

- **ការរៀបចំទ្រុងសំរាប់មាន់តូចដេក** : ទ្រុងសំរាប់មាន់តូចដេក គឺគាត់រៀបចំមានទំហំ ១ x ២,៥ ម៉ែត្រ កំពស់ ០,៥ ម៉ែត្រ ទ្រុងធ្វើឡើងពីឈើឬស្សី និងសំណាញ់នៅក្នុងទីធ្លា ។
- **ទីធ្លាទ្រុង:** គាត់បានធ្វើរបងព័ទ្ធជុំវិញទីធ្លា គឺដើម្បីកុំឲ្យមាន់ចេញក្រៅដើរស៊ីចំណីផ្តេសផ្តាស នាំឲ្យឆ្លងជំងឺ ។ ចំពោះរបងព័ទ្ធជុំវិញទីធ្លាគាត់ធ្វើពីឬស្សីកំពស់ ២ ម៉ែត្រ ការពារមាន់ហើរចេញ ។

## ២. ការថែទាំមាន់

ចំពោះការថែទាំគាត់បានយកចិត្តទុកដាក់នៅគ្រប់ដំណាក់កាលដូចជា :

- នៅពេលកូនមាន់ញាស់ភ្លាម គាត់បានបង្ខាំងមិនឲ្យកូនមាន់ស៊ីចំណីរយៈពេល ២៤ ម៉ោង ។ បន្ទាប់មកគាត់ដាក់ចំណីឲ្យស៊ី ដូចជាស្លឹកកន្ទំថេត បុកលាយជាមួយចុងអង្ករដាក់ឲ្យមាន់ស៊ី។
- នៅពេលមាន់មានអាយុ ១៥ ថ្ងៃ គាត់ចាប់មាន់បំបែកពីមេ យកទៅដាក់នៅក្នុង



**ការផ្តល់ថ្នាំការពារជំងឺមាន់**

ទ្រុង ។ ធ្វើដូចនេះគឺអាចជួយឲ្យកូនមាន់ធាប់ធំ ឆាប់តិចតួច ឬមិនឆាប់ និងមេធាប់រកឈ្មោល ។ មាន់អាយុ ៤០-៤៥ ថ្ងៃ គាត់យកវាចេញពីទ្រុងតូចទៅដាក់ក្នុងទ្រុងធំ (ទ្រុងធ្លា) ដើម្បីឲ្យវាអាចដើររកស៊ីចំណីបន្ថែម ។ ក្រៅពីត្រាំសំបករុក្ខជាតិឲ្យមាន់ផឹក គាត់បានបោសសំអាតទីធ្លា ២-៣ ដងក្នុង ១ សប្ដាហ៍ ។

- គាត់បានលាងសំអាតទ្រុងនៅពេលប្រមូលមាន់លក់ម្ដងៗ ។ ក្រោយពីលាងសំអាត គាត់បានយកដីខ្សាច់ចាក់ពីលើដីក្រោមទ្រុង ដែលមានលាមកមាន់ ដើម្បីបំបាត់មេរោគ ។



ទិដ្ឋភាពមាន់កំពុងស៊ីចំណី

- ដើម្បីការពារស្រមើរក្នុងសំបុកពេលមាន់កំពុងពង គាត់បានជ្រើសរើសនូវវិធីការពារមួយចំនួនដូចជា យកស្លឹកស្ដៅ ស្លឹកទៀប ស្លឹកគ្រៃ ទៅលាយជាមួយចំបើង ដើម្បីធ្វើសំបុក។ នៅពេលមាន់កំពុងពងគាត់បានធ្វើការបង្វិលពងមាន់ជាប្រចាំ ដើម្បីជួយឲ្យពងមាន់មានកំដៅស្មើគ្នា សំរួលដល់ការញាស់របស់កូន ។ ក្រោយពេល ៥ ទៅ ៦ ថ្ងៃត្រូវយកស៊ុតមកឆ្លុះមើលតើវាបង្កកំណើតឬទេ ? ធ្វើដូចនេះ ជៀសវាងពងមាន់ខូច ។
- ប្រភេទចំណីដែលគាត់បានលាយឲ្យមាន់ស៊ីដូចជា កន្ទក់ ស្រូវ ចុងអង្ករ ត្រកួន ស្លឹកអង្គារដី ស្លឹកកន្ទុំថេត ស្លឹកបាស ។

១. **ចំណីសំរាប់កូនមាន់** : សំរាប់កូនមាន់ គាត់បានដាក់ប្រភេទចំណីដូចជា ស្លឹកបាស ត្រកួន កន្ទុំថេត ម្ទេស ស្ករត្នោត ។ មុនឲ្យកូនមាន់ស៊ីគាត់យកចំណីទៅបុកឲ្យម៉ដ្ឋបញ្ចូលគ្នា ហើយការដាក់ម្ទេសនេះគឺដើម្បីជួយកាត់ស្លេស៍កូនមាន់ និងការពារផ្ដាសសាយ ។

២. **ចំណីសំរាប់មាន់ធំ** : អង្ករត្រាំ ២ ម៉ោង ស្លឹកបាស ត្រកួន ម្រុំ កន្ទុំថេត យកទៅហាន់ឲ្យល្អិត អំបិលកន្លះស្លាបព្រា ម្ទេស ១ ទៅ ២ គ្រាប់ ប្របល់ឲ្យសព្វជាមួយស្ករត្នោតគាត់ដាក់ចំណី និងទឹកនៅក្នុងបំពង់ឫស្សី ដើម្បីជួយកុំឲ្យចំណីនិងទឹកប្រឡាក់ប្រឡូកជាមួយដី។

## ៤. ថ្នាំការពារកុំឱ្យមាន់ឈឺ

### ក.វត្ថុធាតុផ្សំ

- ពន្លៃ ចំនួន ១ ខាំ
- ក្បាលខ្ទាយចំនួន ១ ខាំ
- មើមខ្ទឹម ស ចំនួន ១ខាំ
- ស្រាសចំនួន ០,៥ លីត្រ (កំរិត ៣០ ទៅ ៤០សេសេ)

⇒ ខ្អែប ឬមេរងតាមមាន (ក្អែបនៅរស់ ល្អជាងក្អែបងាប់) ។

ខ.របៀបធ្វើ

យកខ្ទាយ ពន្លៃ និងមើមខ្ទឹមសលាងឲ្យស្អាត បន្ទាប់មកហាន់ជាចំណិតស្តើងៗរួចហើយទើបយកច្រកចូលទៅក្នុងដប ដែលមានចំណុះ ០,៥ លីត្រ ក្រោយមកយកក្អែបទាំងរស់ដាក់ក្នុងដបរួចហើយចាក់ស្រាសចូលជាការស្រេច ។ ក្រោយពីបានផ្សំថ្នាំរួចរាល់ គាត់បានយកទៅរក្សាទុកនៅកន្លែងដែលមានម្លប់រយៈពេល ១៥ថ្ងៃ ទើបយកទៅព្យាបាលមាន់ ។

គ.របៀបប្រើប្រាស់និងព្យាបាលជំងឺមាន់

ថ្នាំនេះ គាត់យកទៅព្យាបាលទៅលើជំងឺមាន់ដូចជា ក្អក ហៀរសំបោរ រលាកផ្លូវដង្ហើម និងមិនស៊ីចំណីជាដើម ។ ចំពោះវិធីព្យាបាលមានបង្ហាញជូនដូចតទៅ :



ទិដ្ឋភាពការលាយចំណីឱ្យមាន់ស៊ី

- សំរាប់មាន់ដែលមានទំងន់ ៨ ខាំ គាត់យកស៊ីរាំងបូមថ្នាំចេញពីដប ចំនួន ០,៥ សេសេ សំរាប់ព្យាបាលមាន់មួយក្បាល
- សំរាប់មាន់ដែលមានអាយុចាប់ពី ១៥ថ្ងៃ គាត់យកស៊ីរាំងបូមថ្នាំចេញពីដបចំនួន ០,៣ សេសេសំរាប់ព្យាបាលមាន់មួយក្បាល
- សំរាប់មាន់មួយក្បាលដែលមានទំងន់ ១គីឡូក្រាម ឡើងទៅ គាត់យកស៊ីរាំងបូមថ្នាំចេញពីដបចំនួន ១ សេសេ ។

ជាលទ្ធផលក្រោយពេលច្រកថ្នាំបានរយៈពេល ១ ទៅ ២ ម៉ោង គាត់សង្កេតឃើញថាមាន់ចាប់ផ្តើមឃ្លានចំណីវិញដូចមាន់ធម្មតា ។

## ៥. ចំណាប់អារម្មណ៍

ក្រោយការអនុវត្តទទួលបានជោគជ័យ ធ្វើឲ្យការចិញ្ចឹមមាន់របស់គាត់ពីមួយឆ្នាំទៅមួយឆ្នាំមានការប្រសើរឡើង ពិសេសប្រាក់ចំណូល គឺមានការកើនឡើងជាងមុនច្រើន ។ ក្នុងមួយឆ្នាំគាត់អាចលក់មាន់បានចាប់ពី ១.២០០.០០០រៀល ឡើងទៅ ។ ហើយបើបងប្អូនកសិករមានចំណាប់អារម្មណ៍ អាចយកបទពិសោធន៍នេះទៅធ្វើការសាកល្បងតាម នោះពិតជាអាចដឹងនូវលទ្ធផលជាក់ជាមិនខាន។

**សរុបមក   បច្ចេកទេសសំខាន់ៗក្នុងការចិញ្ចឹមមាន់មានៈ**

- ធ្វើរបងព័ទ្ធទីធ្លា និងទ្រុងសំរាប់មាន់ដេក និងក្រាបពងក្នុងទ្រុងទីធ្លា
- ផ្តល់ចំណីឲ្យកូនមាន់និងមាន់ធំឲ្យបានគ្រប់គ្រាន់ និងទឹក
- ផ្តល់ថ្នាំការពារមាន់ឈឺជាប់ជាប្រចាំ
- ថែទាំ ការពារ ធ្វើអនាម័យសំអាតទ្រុង និងធ្វើថ្នាំធម្មជាតិការពារកុំឲ្យមាន់ឈឺ។

**ស៊ិន   អង្គារសោធ   និង   យ៉ា   ចាន់នី**